**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមគោរពជូន**

**ឯកឧត្តម ណៃ ប៉េណា**

**អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

***ឯកឧត្តម ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ក្នុងឱកាសដ៏នក្ខត្តឫក្ស វិសេសវិសាល ប្រកបដោយមហាកិត្តិយសបំផុត ដែល**ឯកឧត្តម**ត្រូវបានអង្គព្រឹទ្ធសភាទាំងមូល បោះឆ្នោតជ្រើសតាំងជាអនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៥ ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និង សិប្បកម្មគ្រប់លំដាប់ថ្នាក់ ក៏ដូចជាមន្ត្រីក្នុងក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាកក់ក្តៅ ប្រកបដោយមនោសញ្ចេតនារំភើប រីករាយក្រៃលែង ជូនចំពោះ **ឯកឧត្តម អនុប្រធានទី១ ព្រឹទ្ធសភា និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារទាំងអស់។

ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា មានជំនឿយ៉ាងមុតមាំថា ជាមួយនឹងសមត្ថភាព បទពិសោធន៍ការងារដ៏ខ្ពង់ខ្ពស់ រួមទាំងភាពចាស់ទុំខាងនយោបាយផងនោះ **ឯកឧត្តម** នឹងរួមចំណែកដឹកនាំស្ថាប័នព្រឹទ្ធសភាឱ្យបន្តទទួលបានជោគជ័យ រីកចម្រើន រឹងមាំថែមទៀត ដើម្បីពង្រឹងស្ថាប័ននីតិបញ្ញត្តិ ពង្រឹងនីតិរដ្ឋ ការកសាងអភិវឌ្ឍសេដ្ឋកិច្ច សង្គមលើគ្រប់វិស័យ និងការពារបានរដ្ឋធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ ដែលជាបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា។

ឆ្លៀតឱកាសដ៏ឧត្តុងឧត្តមនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម** និងសូមប្រសិទ្ធពរជ័យជូនចំពោះ **ឯកឧត្តម និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមអនុប្រធានទី១ ព្រឹទ្ធសភា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និងកក្តីភាពដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៥

**តំណាងថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ទេសរដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**